**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :..០៨.៩៩.៩៣៨**

## សារាចរណែនាំ

## ស្តីពី

## ការចាត់តាំងខួបអន្តរជាតិលើកទី ១២១

## នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០០៧

***ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា*** គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិដែលចាប់ផ្តើមនា ឆ្នាំ ១៨៨៦ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពនៃលក្ខខណ្ឌការងារ និងជីវភាពរស់នៅរបស់ប្រជាពលករ ។ នៅកម្ពុជា ***ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា*** ត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំតាំងពីឆ្នាំ ១៩៧៩ ហើយមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានកំណត់យកថ្ងៃទី ១ ខែ ឧសភា គឺជាថ្ងៃបុណ្យការងាររបស់ពលករកម្ពុជា និងជាថ្ងៃឈប់សំរាករបស់មន្ត្រីរាជការ ក៏ដូចជាកម្មករនិយោជិត ។ ជារៀងរាល់ឆ្នាំ មានស្ថាប័នរដ្ឋ និងសហគ្រាស គ្រឹះស្ថានឯកជនជាច្រើនបានរៀបចំអបអរសាទរ និងប្រារព្ធទិវានេះ ក្នុងបរិយាកាសសប្បាយរីករាយ និងសាមគ្គីភាពគួរឱ្យកត់សម្គាល់ ។

ឆ្នាំ ២០០៧ នេះ យើងទាំងអស់គ្នានៅតែបន្តយក ***ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា*** ជាថ្ងៃប្តេជ្ញាចិត្តលើកកំពស់ការអនុវត្តលក្ខខណ្ឌការងារ និងធានាសិទ្ធិប្រយោជន៍កម្មករ និយោជិតតាមច្បាប់ស្តីពីការងារ ជាពិសេសការអនុវត្តន៍ស្មារតីអនុសញ្ញាអន្តរជាតិខាងការងារចំនួន ១៣ ក្នុងនោះមានអនុសញ្ញាស្នូលចំនួន ៨ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នរួចមកហើយ ។ ទន្ទឹមនឹងនេះ យើងទាំងអស់គ្នាក៏ត្រូវកំណត់យកទិវានេះ ជាថ្ងៃប្តេជ្ញាចិត្តក្នុងការបង្កើនគុណភាពផលិតផលសម្រាប់ការប្រកួតប្រជែង ក៏ដូចជាការរក្សាចិរភាពសហគ្រាសគ្រឹះស្ថាន ដើម្បីការអភិវឌ្ឍន៍ជាតិ និងការលើកកំពស់ជីវភាពប្រជាពលរដ្ឋ ។

អាស្រ័យហេតុនេះ ដើម្បីរៀបចំការប្រារព្ធខួបលើកទី ១២១ នៃ ***ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ឧសភា ឆ្នាំ ២០០៧*** នេះ ប្រព្រឹត្តទៅបានល្អ រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំដូចខាងក្រោមនេះ ÷

១. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវចេញសេចក្តីជូនដំណឹងដើម្បីណែនាំអំពីការឈប់សម្រាក និងបំផុសការជួបសំណេះសំណាល ការជួបជុំជប់លៀងកំសាន្តសប្បាយ ការដើរកំសាន្តតាម

រូបភាព និងលទ្ធភាពរៀងៗខ្លួនរបស់សហគ្រាស គ្រឹះស្ថានសំដៅបង្កបរិយាកាសសាមគ្គីភាព ភាតរភាព រវាងកម្មករនិយោជិត និងនិយោជក ។ ថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវជ្រើសរើសរោងចក្រមួយជានិមិត្តរូប ដើម្បីចូលរួមកម្មវិធីកំសាន្តសប្បាយរីករាយ និងធ្វើការសំណេះសំណាលជាមួយកម្មករនិយោជិត ។

២. ក្រសួងព័ត៌មានត្រូវណែនាំប្រព័ន្ធឃោសនារបស់រដ្ឋ និងឯកជនទទួលផ្សព្វផ្សាយ *សារលិខិតរបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី ១២១ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០០៧* ឱ្យបានទូលំទូលាយ ។

៣. ក្រសួងមហាផ្ទៃ អគ្គស្នងការនគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អាជ្ញាធរខេត្តក្រុង និងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវតែមានការណែនាំកម្លាំងសមត្ថកិច្ចរបស់ខ្លួន ក្នុងការថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងឱកាស *ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា* ឆ្នាំ ២០០៧ នេះ ។

៤. សាលាខេត្ត- ក្រុងត្រូវចាត់ចែងការចងបដាពាក្យស្លោកនៅតាមដងវិថីសំខាន់ៗ ជាពិសេសនៅក្នុងរាជធានីភ្នំពេញ ។ ដោយឡែក ក្រសួងស្ថាប័ន អង្គភាពរដ្ឋ និងសហគ្រាសគ្រឹះស្ថានឯកជនគ្រប់ខេត្ត- ក្រុងត្រូវចងបដាពាក្យស្លោកថា *«អបអរសាទរខួបអនុស្សាវរីយ៍លើកទី ១២១ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០០៧»* នៅពីមុខអគាររៀងៗខ្លួន ។

រាជរដ្ឋាភិបាលកម្ពុជាសូមអំពាវនាវដល់អង្គការវិជ្ជាជីវៈ សមាគម និងប្រជាពលរដ្ឋទាំងអស់ សូមចូលរួមអបអរសាទរ *ទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០០៧* ក្នុងសេចក្តីរីករាយ សាមគ្គីភាព និងភាតរភាព ដើម្បីឱ្យស័ក្តិសមជាបុណ្យការងាររបស់ប្រទេសជាតិយើង។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់ខេត្ត- ក្រុង រៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

*រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មេសា ឆ្នាំ ២០០៧*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន និងខេត្ត- ក្រុង*
- *ឯកសារ- កាលប្បវត្តិ*